## ចំណុចសំខាន់ៗបួន ដែលសិស្សានុសិស្សគួរដឹងអំពីការប្រឡង PSSA ថ្មី

១. ការប្រឡង PSSA នៅក្នុងថ្នាក់របស់អ្នកកាលពីនិទាឃរដូវកន្លងទៅនេះ ប្រហែលជាមានការលំបាកជាងការប្រឡង PSSAs ដែលអ្នកបានប្រឡងកាលពីមុន។ នោះដោយសារការវាយតម្លៃនេះបានធ្វើឡើងដើម្បីវាយតម្លៃមូលដ្ឋាននៃកម្មវិធីសិក្សាថ្មី របស់រដ្ឋផិនស៊ីលវេញ៉ា (PA Core)។ រដ្ឋផិនស៊ីលវេញ៉ាបានអនុម័តយក PA Core ក្នុងឆ្នាំ២០១៣ ដើម្បីជួយសិស្សានុសិស្ស ដូចជារូបអ្នក បន្ថែមទៀតក្នុងការត្រៀមខ្លួនសម្រាប់ មហាវិទ្យាល័យ និង អាជីព នៅពេលដែលអ្នកបញ្ចប់ការសិក្សាពីវិទ្យាល័យ។

២. អ្វីៗមួយចំនួនដែលអ្នកសិក្សានៅក្នុងថ្នាក់ គឺគេឆាប់បង្រៀនជាងពីមុន ហេតុនេះហើយអាចធ្វើឲ្យការប្រឡងនេះកាន់តែមានការលំបាកជាងមុន។ ជាបន្ថែមទៀត ការវាយតម្លៃថ្មីនេះ រួមបញ្ចូល ចំណោទ ការសរសេរ និងការត្រិះរិះស៊ីជម្រៅ ច្រើនជាងការវាយតម្លៃកាលពីមុន។

៣. ការប្រឡង PSSA មានបួនកម្រិត៖ ក្រោមមូលដ្ឋាន មូលដ្ឋាន ស្ទាត់ជំនាញ និង កម្រិតខ្ពស់ (Below Basic, Basic, Proficient and Advanced)។ ដោយសារការប្រឡងមានការលំបាកជាងមុន អ្នកប្រហែលជាធ្វើមិនបានល្អដូចពេលដែលអ្នកបានប្រឡងពីមុននោះទេ អញ្ចឹងក៏មិនអីដែរ។ គ្រូ និងមាតាបិតា ដឹងថា បើអ្នកសិក្សាកម្មវិធីសិក្សាថ្មីនេះកាន់តែយូរ អ្នកនឹងធ្វើបានកាន់តែល្អ។

៤. គ្រូ និងសាលា របស់អ្នក ខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍកម្មវិធីសិក្សាថ្មីឲ្យស្របតាម PA Core ថ្មី ដើម្បីជួយអ្នកឲ្យរៀនពូកែ មិនមែនសម្រាប់តែការប្រឡងនោះទេ ប៉ុន្តែជួយអ្នកឲ្យមានជោគជ័យក្នុងការសិក្សា និងនៅពេលដែលអ្នករៀនចប់។